# របាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា ប្រចាំខែមករា ឆ្នាំ២០២០

## Cambodian Rice Export Summary Report January 2020

ស.អ.ក
សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

#2C, Street 120, Sangkat Phsar Tmey II, Khan Daun Penh, Phnom Penh, Cambodia

www.crf.org.kh    info@crf.org.kh    (855) 23 559 8999

**ការនាំចេញអង្កររបស់កម្ពុជា** ក្នុងខែមករា ឆ្នាំ២០២០ បានចំនួន **៥០,៤៥០តោន** ដែលក្នុងនោះ អង្ករក្រអូប **៩១%** ស្មើនឹង **៤៦,០០៦តោន** ហើយអង្ករសគ្រាប់វែង មានចំនួន **៩%** ឬ **៤,៤៤៤តោន**។ ការនាំចេញក្នុងខែមករា ឆ្នាំ២០២០ មានការថយចុះចំនួន **១៥.៣៩%** ស្មើចំនួន **៩,១៧៥តោន**។

ស្ថានភាពជារួម **សហគមន៍អឺរ៉ុប**នៅតែបន្តឈានមុខគេសម្រាប់ទីផ្សារអង្ករកម្ពុជា ដែលកាន់កាប់ចំណែកទីផ្សារដល់ទៅចំនួន **៣៧%** ស្របពេលដែល**ប្រទេសចិនចំនួន ៣០% អាស៊ាន ចំនួន ១១% និងបណ្តាប្រទេសផ្សេងៗទៀតចំនួន ២២%**។

ការនាំចេញអង្ករនេះមានការថយចុះទៅសហគមន៍អឺរ៉ុប មានចំនួន **២២%** ស្មើនឹងបរិមាណចំនួន **៥,២៦៩តោន** បើធៀបទៅនឹងរយៈពេលដូចគ្នា នៅខែមករា ឆ្នាំ២០១៩។ តាមការសង្កេតជារួម មូលហេតុ នៃការថយចុះនេះ បណ្តាលមកពីការយកពន្ធអង្ករកម្ពុជានាំចូលនៅសហគមន៍អឺរ៉ុប នៅឆ្នាំដំបូង ក្នុងអង្ករមួយតោនចំនួន **១៧៥អឺរ៉ូ** ដោយគិតចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ មក។ ទោះបីជាមានការយកពន្ធលើការនាំចូលអង្ករពីកម្ពុជាក៏ដោយ ក៏ទីផ្សារអង្ករកម្ពុជាមានស្ថានភាពប្រែប្រួល ដោយប្តូរពីការនាំចេញអង្ករសគ្រាប់វែង អង្ករចំហុយ និង អង្ករក្រអូប ទៅជា អង្ករក្រអូប វិញស្ទើរទាំងស្រុង ទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប ដែលអាចប៉ាន់ប្រមាណថា បរិមាណទឹកប្រាក់ដែលបានពីការនាំអង្ករចេញទៅសហគមន៍អឺរ៉ុបមានបរិមាណប្រហាក់ប្រហែលនឹងឆ្នាំ២០១៩។

### គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា សម្រាប់ខែមករា ឆ្នាំ២០២០




### បរិមាណនាំចេញ ក្នុងខែមករា ២០២០ តាមទីផ្សារគោលដៅ ធៀបនឹងខែដូចគ្នា ឆ្នាំ២០១៩




ចំពោះការនាំអង្ករចេញទៅកាន់ប្រទេសចិនក្នុងខែមករា ឆ្នាំ២០២០នេះ បានថយចុះផងដែរ ប្រមាណជា **២០% ឬ ៣,៦៦៤តោន**។ បើសង្កេតជារួមលើមូលហេតុនៃការថយចុះនេះ គឺបណ្តាលមកពីការប្រារព្ធពិធីចូលឆ្នាំថ្មីឆ្នាំចិននៅប្រទេសចិន ធ្វើឡើងនៅក្នុងមករា ឆ្នាំ២០២០ ដែលលឿនជាងការចូលឆ្នាំចិននៅឆ្នាំ២០១៩ នៅដើមខែកុម្ភៈ។ ហេតុនេះហើយបានជាការធ្វើការបញ្ជាទិញ និងដំណើរការដឹកជញ្ជូន ត្រូវឈប់សម្រាក ក្នុងរយៈពេលជាមធ្យមប្រមាណជា២សប្តាហ៍។

ចំណែកឯទីផ្សារអាស៊ានវិញ ឃើញថាមានការប្រែប្រួលខ្លះ អាស្រ័យលើប្រទេសជិតខាងដូចជាប្រទេសថៃ និងវៀតណាម។ ទន្ទឹមនឹងនោះ ទីផ្សារចម្បងរបស់កម្ពុជា គឺប្រទេសម៉ាឡេស៊ី និងព្រុយណេ ដែលមិនមានការប្រែប្រួលខ្លាំងនោះទេ គឺនៅរក្សាបានស្ថានភាពល្អ មានលំនឹងនៅឡើយ។

រីឯទីផ្សារផ្សេងៗទៀត បានកើនឡើងប្រមាណ ៤០% ក្នុងនោះប្រទេសកាប៉ុង នៅតែបន្តនាំមុខដដែល ស្របពេលជាមួយគ្នានោះ ប្រទសអូស្ត្រាលី បានបង្កើនល្បឿននាំចូលអង្ករច្រើនពីកម្ពុជាគួរឱ្យកត់សម្គាល់ផងដែរ។

ទឹកប្រាក់សរុបពីការនាំអង្ករចេញពីកម្ពុជា ក្នុងខែមករា ឆ្នាំ២០២០ មានប្រមាណជា **៣៩លានដុល្លារអាមេរិក**។

ប្រភពស្ថិតិនាំចេញ ៖ លេខាធិការដ្ឋានច្រកចេញចូលតែមួយ សម្រាប់បំពេញបែបបទនាំចេញអង្ករ ខែមករា ឆ្នាំ២០២០។
ដកស្រង់ និងវិភាគដោយ៖ លោក លន់ យ៉េង អគ្គលេខាធិការនៃលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា